ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសជប៉ុន

សេចក្តីថ្លែងការណ៍ព័ត៌មាន

ស្តីពីអត្ថបទរបស់ទីភ្នាក់ងារសារព័ត៌មាន Jiji Press ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២៦ ពាក់ព័ន្ធនឹងទណ្ឌិត សម រង្ស៊ី

ទីក្រុងតូក្យូ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៦

ស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន សូមសម្តែងនូវការជំទាស់យ៉ាងខ្លាំងចំពោះអត្ថបទព័ត៌មានដែលចេញផ្សាយដោយទីភ្នាក់ងារសារព័ត៌មាន Jiji Press កាលពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២៦ ស្តីពីបទសម្ភាសន៍ជាមួយ សម រង្ស៊ី នៅទីក្រុងតូក្យូ ដែលមានខ្លឹមសារពណ៌នាអំពីស្ថានភាពនយោបាយនៅកម្ពុជា ក្នុងលក្ខណៈបំភាន់ និងខុសឆ្គងយ៉ាងធ្ងន់ធ្ងរ ព្រមទាំងបានផ្តល់វេទិកាសម្រាប់ការចោទប្រកាន់មកលើរាជរដ្ឋាភិបាលកម្ពុជា ដោយពុំបានឆ្លុះបញ្ចាំងឱ្យបានគ្រប់ជ្រុងជ្រោយនូវបរិបទច្បាប់ និងរដ្ឋធម្មនុញ្ញដែលពាក់ព័ន្ធ។

ស្ថានឯកអគ្គរាជទូត សូមច្រានចោលយ៉ាងដាច់អហង្ការចំពោះការពណ៌នារបស់អត្ថបទព័ត៌មាននេះអំពីប្រព័ន្ធនយោបាយកម្ពុជា និងកាលៈទេសៈជុំវិញការរំលាយអតីតគណបក្សសង្គ្រោះជាតិ (CNRP)។ ការផ្សព្វផ្សាយក្នុងលក្ខណៈបែបនេះ អាចនាំឱ្យសាធារណជនមានការយល់ឃើញខុសពីការពិត និងទទួលបានព័ត៌មានតែម្ខាងអំពីកិច្ចការនយោបាយផ្ទៃក្នុងរបស់កម្ពុជា ដោយមិនបានយកចិត្តទុកដាក់ចំពោះក្របខ័ណ្ឌរដ្ឋធម្មនុញ្ញ ស្ថាប័នតុលាការ និងនីតិវិធីច្បាប់ជាធរមានរបស់ប្រទេស។

ព្រះរាជាណាចក្រកម្ពុជា គឺជារដ្ឋអធិបតេយ្យមួយ ដែលគ្រប់គ្រងដោយផ្អែកលើរដ្ឋធម្មនុញ្ញ ដោយស្ថាប័ននានាដែលត្រូវបានបង្កើតឡើងស្របតាមរដ្ឋធម្មនុញ្ញ អនុវត្តតួនាទី និងភារកិច្ចរៀងៗខ្លួន ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ដំណើរការនយោបាយ និងការបោះឆ្នោតនៅកម្ពុជា ត្រូវបានអនុវត្តក្នុងក្របខ័ណ្ឌរដ្ឋធម្មនុញ្ញ និងច្បាប់នេះ។ ដូច្នេះ រាល់ការវាយតម្លៃអំពីការវិវត្តនៃស្ថានភាពនយោបាយនៅកម្ពុជា គប្បីពិចារណាឱ្យបានហ្មត់ចត់អំពីសណ្តាប់ធ្នាប់រដ្ឋធម្មនុញ្ញ និងការបំពេញមុខងាររបស់ស្ថាប័នជាតិរបស់កម្ពុជា។

ពាក់ព័ន្ធនឹងការរំលាយអតីតគណបក្សសង្គ្រោះជាតិ ក្នុងឆ្នាំ២០១៧ ស្ថានឯកអគ្គរាជទូត សូមរំលឹកថា សេចក្តីសម្រេចនេះត្រូវបានប្រកាសដោយតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមក្របខ័ណ្ឌច្បាប់ជាធរមាន។ កាលៈទេសៈនៃសេចក្តីសម្រេចរបស់តុលាការនេះ មិនគួរត្រូវបានលើកយកមកបង្ហាញដោយកាត់ផ្តាច់ចេញពីនីតិវិធីច្បាប់ និងបរិបទរដ្ឋធម្មនុញ្ញដែលជាមូលដ្ឋាននៃសេចក្តីសម្រេចនោះឡើយ។

8-6-9 AKASAKA, MINATO-KU, TOKYO 107-0052
Tel : +81 3-5412-8521 Fax: +81 3-5412-8526
Email: camemb.jpn@mfaic.gov.kh

ស្ថានឯកអគ្គរាជទូត សូមទាញការយកចិត្តទុកដាក់បន្ថែមចំពោះការពិតដែលថា សម រង្ស៊ី ត្រូវបានតុលាការកម្ពុជាផ្តន្ទាទោសក្នុងសំណុំរឿងព្រហ្មទណ្ឌនានា។ រចនាសម្ព័ន្ធនយោបាយដែលបុគ្គលរូបនេះបានប្រកាសបង្កើតឡើងដោយខ្លួនឯងនៅក្រៅប្រទេស ពុំមានមូលដ្ឋានអំណាចស្របតាមរដ្ឋធម្មនុញ្ញ ឬច្បាប់ ដើម្បីធ្វើជាតំណាងឱ្យព្រះរាជាណាចក្រកម្ពុជាឡើយ។ បញ្ហាទាំងនេះគឺជាព័ត៌មានមូលដ្ឋានសំខាន់ៗ ដែលគួរត្រូវបានយកមកពិចារណានៅពេលធ្វើសេចក្តីរាយការណ៍អំពីសកម្មភាព និងការអះអាងផ្នែកនយោបាយរបស់បុគ្គលរូបនេះ។

ស្ថានឯកអគ្គរាជទូត សូមគូសបញ្ជាក់ថា **ព្រះរាជាណាចក្រកម្ពុជា និងប្រទេសជប៉ុនមានទំនាក់ទំនងដ៏ល្អប្រសើរ ដែលត្រូវបានកំណត់លក្ខណៈដោយចំណងមិត្តភាពដ៏យូរអង្វែង ការជឿទុកចិត្តគ្នាទៅវិញទៅមក ការគោរពគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធលើវិស័យជាច្រើន។** ទំនាក់ទំនងទាំងនេះត្រូវបានយកចិត្តទុកដាក់ថែរក្សា និងពង្រឹងអស់រយៈពេលជាច្រើនឆ្នាំមកហើយ ហើយនៅតែមានសារៈសំខាន់យ៉ាងខ្លាំងចំពោះប្រទេសទាំងពីរ។

ក្នុងបរិបទនេះ ស្ថានទូតយល់ឃើញថា វាមានសារៈសំខាន់ជាពិសេសដែលថ្នាក់ដឹកនាំផ្នែកវិចារណកថារបស់ទីភ្នាក់ងារសារព័ត៌មាន Jiji Press គួរពិចារណាឱ្យបានហ្មត់ចត់អំពីបរិបទទូលំទូលាយនៃទំនាក់ទំនងកម្ពុជា-ជប៉ុន នៅពេលធ្វើការរាយការណ៍អំពីបញ្ហាពាក់ព័ន្ធនឹងប្រទេសកម្ពុជា។ ការរាយការណ៍ព័ត៌មានប្រកបដោយការទទួលខុសត្រូវ និងតុល្យភាព ដោយផ្អែកលើភាពត្រឹមត្រូវនៃអង្គហេតុ និងការបង្ហាញទស្សនៈពាក់ព័ន្ធដោយយុត្តិធម៌ អាចរួមចំណែកដល់ការយោគយល់គ្នាទៅវិញទៅមករវាងប្រជាជននៃប្រទេសទាំងពីរ និងជួយរក្សាបរិយាកាសនៃមិត្តភាព និងការជឿទុកចិត្ត ដែលជាលក្ខណៈសម្គាល់នៃទំនាក់ទំនងទ្វេភាគីរបស់ប្រទេសទាំងពីរ។

ស្ថានទូតព្រះរាជាណាចក្រកម្ពុជាគោរពយ៉ាងពេញលេញចំពោះសេរីភាពសារព័ត៌មាន និងឯករាជ្យភាពផ្នែកវិចារណកថា។ ទន្ទឹមនឹងនេះ ស្ថានទូតរំពឹងថា ការរាយការណ៍ព័ត៌មានពាក់ព័ន្ធនឹងប្រទេសកម្ពុជានឹងត្រូវបានអនុវត្តដោយមានការប្រុងប្រយ័ត្ន និងការយកចិត្តទុកដាក់ខ្ពស់ ដោយធានានូវភាពត្រឹមត្រូវ យុត្តិធម៌ និងការគិតគូរឱ្យបានសមស្របចំពោះភាពខុសគ្នារវាងការចោទប្រកាន់ផ្នែកនយោបាយ និងអង្គហេតុដែលត្រូវបានបញ្ជាក់ជាផ្លូវការ។

ស្ថានទូតសូមអំពាវនាវដល់ទីភ្នាក់ងារសារព័ត៌មាន Jiji Press ឱ្យយកចិត្តទុកដាក់ពិចារណាឱ្យបានហ្មត់ចត់ចំពោះកង្វល់ទាំងនេះ និងធានាថា ទស្សនៈពាក់ព័ន្ធនឹងផ្នែកច្បាប់ រដ្ឋធម្មនុញ្ញ និងផ្លូវការរបស់ស្ថាប័នមានសមត្ថកិច្ច ត្រូវបានឆ្លុះបញ្ចាំងឱ្យបានសមស្របនៅក្នុងការរាយការណ៍ព័ត៌មានរបស់ខ្លួន។

ស្ថានទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន

ទីក្រុងតូក្យូ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៦